dk-cl

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តក្រចេះ

លេខ: ៥៤ ដ.ក្រច

ក្រចេះ,ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១០

មកដល់ថ្ងៃទី ១៨.៥.២០១០
ម៉ោង ៤:១៥នាទី
លេខ ១៥៤

# ដីកា

## ស្តីពីការធ្វើប្រតិភូកម្មលើឯកសារថតចម្លងផ្សេងៗ ទៅឱ្យសាលាក្រុងក្រចេះ ក្នុងការអនុវត្តគម្រោងការិយាល័យច្រកចេញចូលតែមួយ

## អភិបាលខេត្តក្រចេះ

- បានឃើញព្រះរាជក្រឹត្យ នស/រកត / ០៥០៩ / ៥៤៦ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តក្រចេះ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- បានឃើញប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ១៥-០២-១៩៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។
- យោងលិខិតលេខ ៦៤៣ សជណ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ ។

## សម្រេច

**ប្រការ១:** ត្រូវបានធ្វើប្រតិភូកម្មលើឯកសារថតចម្លងផ្សេងៗ ទៅឱ្យសាលាក្រុងក្រចេះនៃគម្រោងការិយាល័យច្រកចេញចូលតែមួយ ដូចមានរាយមុខខាងក្រោម :-

១- វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា

២- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាភិរត១

៣- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាភិរត

៤- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ

៥- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ

៦- វិញ្ញាបនប័ត្របញ្ចប់ការសិក្សាថ្នាក់ទី១២

៧- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម

៨- វិញ្ញាបនប័ត្រប្រកបអាជីវកម្ម

៩- វិញ្ញាបនប័ត្រ

១០- លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត១

១១- សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ( បំពេញវិជ្ជា )

១២- សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ

១៣- សញ្ញាប័ត្រមធ្យមសិក្សាគរុកោសល្យ

១៤- សញ្ញាប័ត្រមធ្យមសិក្សា

១៥- សញ្ញាប័ត្រគ្រូបង្រៀនកំរិតឧត្តម

១៦- ព្រឹត្តប័ត្រលទ្ធផលសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ

១៧- បរិញ្ញាប័ត្រ

១៨- បរិញ្ញាប័ត្ររង

១៩- លិខិតបញ្ជាក់ការសិក្សា

២០- អត្តសញ្ញាណប័ណ្ណ

២១- សៀវភៅស្នាក់នៅ

២២- ប័ណ្ណសំគាល់យានយន្ត

២៣- ព្រឹត្តប័ត្រពិន្ទុ

២៤- ពាក្យសុំបញ្ជាក់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ចំណេះដឹងទូទៅ

**ប្រការ២:** សាលាខេត្ត សាលាក្រុងក្រចេះ មានភារកិច្ចអនុវត្តតាមដីកានេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

**អភិបាលខេត្ត**

ខុំ ភឿន

**កន្លែងទទួល**

- ក្រសួងមហាផ្ទៃ
- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត
  " ដើម្បីគោរពជូនជ្រាប "
- ដូចប្រការ២
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

# តារាងតម្លៃសេវានីត្យានុកូលកម្ម

| ល.រ | ប្រភេទលិខិត | តម្លៃសេវាកម្មក្នុងមួយសន្លឹក (គិតជាប្រាក់រៀល) | | |
|---|---|---|---|---|
| | | សេវាប្រតិបត្តិ | តែមប្រើ | ទឹកប្រាក់សរុប |
| ១ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា | 500 | 200 | 700 |
| ២ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាកំរិត១ | 500 | 200 | 700 |
| ៣ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាកំរិត២ | 500 | 200 | 700 |
| ៤ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាបឋមភូមិ | 500 | 200 | 700 |
| ៥ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាទុតិយភូមិ | 500 | 200 | 700 |
| ៦ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា ថ្នាក់ទី១២ | 500 | 200 | 700 |
| ៧ | វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម / ១០%. | 800 | 200 | 1,000 |
| ៨ | វិញ្ញាបនបត្រប្រកបអាជីវកម្ម | 800 | 200 | 1,000 |
| ៩ | វិញ្ញាបនបត្រវិញ្ញាបត្របណ្តោះអាសន្ន | 800 | 200 | 1,000 |
| ១០ | លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកំរិត១ | 500 | 200 | 700 |
| ១១ | សញ្ញាបត្រមធ្យមសិក្សាកំរិត២(បំពេញវិជ្ជា) | 500 | 200 | 700 |
| ១២ | សញ្ញាបត្រមធ្យមសិក្សា ទុតិយភូមិ | 500 | 200 | 700 |
| ១៣ | សញ្ញាបត្រមធ្យមសិក្សា គរុកោសល្យ | 500 | 200 | 700 |
| ១៤ | សញ្ញាបត្រមធ្យមសិក្សា | 500 | 200 | 700 |
| ១៥ | សញ្ញាបត្រគ្រូបង្រៀនកំរិតឧត្តម | 500 | 200 | 700 |
| ១៦ | ព្រឹត្តិបត្រលទ្ធផល ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | 500 | 200 | 700 |
| ១៧ | សញ្ញាបត្របរិញ្ញាបត្រ | 800 | 200 | 1,000 |
| ១៨ | សញ្ញាបត្របរិញ្ញាបត្ររង | 800 | 200 | 1,000 |
| ១៩ | លិខិតបញ្ជាក់ការសិក្សាផ្សេងៗទៀត | 500 | 200 | 700 |
| ២០ | អត្តសញ្ញាណប័ណ្ណ | 500 | 200 | 700 |
| ២១ | សៀវភៅស្នាក់នៅ | 500 | 200 | 700 |
| ២២ | ប័ណ្ណសំគាល់យានយន្ត | 800 | 200 | 1,000 |
| ២៣ | ព្រឹត្តិបត្រពិន្ទុ | 500 | 200 | 700 |
| ២៤ | ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកំរិត២ចំណោះដឹងទូទៅ | 500 | 200 | 700 |